**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ១៨៩ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការបង្កើតសហគ្រាសគ្រប់គ្រងស្ថានីយផ្ទេរ និងទីលានទុកដាក់សំរាម សំណល់រឹង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមិនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦ /២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៥/០១៩ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ១៣៥ អនក្រ.បក ចុះថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ៤១ អនក្រ.បក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការអនុវត្តព្រះរាជក្រមលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៧១ អនក្រ.បក ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១១ ស្តីពីការបំពេញបន្ថែមអនុក្រឹត្យលេខ៤១ អនក្រ.បក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការអនុវត្តព្រះរាជក្រមលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ១១៣ អនក្រ.បក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥ ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- យោងតាមសំណើរួមរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងបរិស្ថាន

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១ ._**

ត្រូវបានបង្កើត "**សហគ្រាសគ្រប់គ្រងស្ថានីយផ្ទេរ និងទីលានចាក់សំរាម សំណល់រឹង**" តទៅនេះសរសេរជាអក្សរកាត់ថា **ស.ធ.ស.** និងសរសេរជាភាសាអង់គ្លេស Enterprise for Managing Transfer Stations and Landfills for Solid Waste (EML)ដែលស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេសរបស់ក្រសួងបរិស្ថាន និងក្រោមអាណាព្យាបាលហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា ២ ._**

**ស.ធ.ស.** ត្រូវបានកំណត់ជាសហគ្រាសសាធារណៈ ក្រោមទម្រង់ជាក្រុមហ៊ុនរដ្ឋ ដែលមានឧបនិស្ស័យជាសហគ្រាសពាណិជ្ជកម្ម និងមានស្វ័យភាពបរិបូរណ៍ ក្នុងការដឹកនាំ និងគ្រប់គ្រងប្រតិបត្តិការរបស់ខ្លួន។

## ជំពូកទី ២
## បេសកកម្ម តួនាទី និងភារកិច្ច

**មាត្រា ៣ ._**

**ស.ធ.ស.** មានបេសកកម្មគ្រប់គ្រងស្ថានីយផ្ទេរ និងទីលានទុកដាក់សំរាម សំណល់រឹង នៃព្រះរាជាណាចក្រកម្ពុជា ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការគ្រប់គ្រងសំរាម សំណល់រឹង និងការអភិវឌ្ឍទីប្រជុំជនប្រកបដោយសោភ័ណភាព ចីរភាព និងសុខុមាលភាព។

**មាត្រា ៤ ._**

**ស.ធ.ស.** មានភារកិច្ច ដូចតទៅ÷

- សិក្សា និងរៀបចំផែនការមេសម្រាប់សាងសង់ និងអភិវឌ្ឍស្ថានីយផ្ទេរ និងទីលានទុកដាក់សំរាម សំណល់រឹង និងហេដ្ឋារចនាសម្ព័ន្ធសមាហរណមួយចំនួនមានជាអាទិ៍ ទីកន្លែងទាញយកធនធាន កន្លែងកែច្នៃ និងរោងចក្របំប្លែងជាថាមពលអគ្គិសនី
- អនុវត្ត និងគ្រប់គ្រងគម្រោងសាងសង់ហេដ្ឋារចនាសម្ព័ន្ធស្ថានីយផ្ទេរ និងទីលានទុកដាក់សំរាម សំណល់រឹង ក្នុងនាមជាភ្នាក់ងារប្រតិបត្តិគម្រោង
- ចាត់ចែង និងគ្រប់គ្រងស្ថានីយផ្ទេរ និងទីលានទុកដាក់សំរាម សំណល់រឹង
- ផ្តល់សេវាផ្ទេរ និងទុកដាក់សំរាម សំណល់រឹង ជូនប្រតិបត្តិករសម្អាត,ប្រមូល និងដឹកជញ្ជូនសំរាមសំណល់រឹង ឯកជន ឬអង្គភាពរដ្ឋ ឬក្រុមហ៊ុនឯកជនផ្សេងទៀត ដែលប្រើប្រាស់សេវាផ្ទេរ និងទុកដាក់ដោយការយកថ្លៃសេវា
- សហការជាមួយរដ្ឋាករស្វយ័តគ្រប់គ្រងសំរាម សំណល់រឹង និងស្ថាប័នរដ្ឋនានា ក្នុងការចែករំលែកទិន្នន័យ និងផ្តល់កិច្ចសហប្រតិបត្តិការចាំបាច់ផ្សេងទៀត ដើម្បីធានាថា យន្តការ និងប្រព័ន្ធគ្រប់គ្រងសំរាម សំណល់រឹងថ្មី អាចអនុវត្តទៅបានដោយជោគជ័យ និងប្រកបដោយប្រសិទ្ធភាពខ្ពស់
- សម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍ វិស័យឯកជន ឬសាធារណជន ក្នុងការកៀរគរធនធានហិរញ្ញវត្ថុ មធ្យោបាយ និងសម្ភារសម្រាប់គាំទ្រលើការងារគ្រប់គ្រងស្ថានីយផ្ទេរ និងទីលានទុកដាក់សំរាម សំណល់រឹង។

**មាត្រា ៥ ._**

**ស.ធ.ស.** ជានីតិបុគ្គលដែលមានបុគ្គលភាពគតិយុត្តពេញលេញស្របតាមច្បាប់កំណត់ ក្នុងកិច្ចប្រតិបត្តិការអាជីវកម្ម និងការផ្តល់សេវាកម្មរបស់ខ្លួន ហើយមានសិទ្ធិពេញលេញតាមផ្លូវច្បាប់ក្នុងការកាន់កាប់ ប្រើប្រាស់ និងចាត់ចែងទ្រព្យសម្បត្តិរដ្ឋ ដោយអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមានពាក់ព័ន្ធនឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ។

**មាត្រា ៦ ._**

ទីស្នាក់ការកណ្តាលបណ្តោះអាសន្នរបស់ **ស.ឆ.ស.** ស្ថិតនៅទីស្តីការក្រសួងបរិស្ថាន។

## ជំពូកទី ៣
## ការដឹកនាំ និងគ្រប់គ្រង

**មាត្រា ៧ ._**

**ស.ឆ.ស.** ត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាលចំនួន ០៧ រូប ដែលមានសមាសភាពដូចតទៅ÷

| | | |
|---|---|---|
| - តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ០១ រូប | ប្រធាន |
| - តំណាងក្រសួងបរិស្ថាន | ០១ រូប | សមាជិក |
| - តំណាងក្រសួងមហាផ្ទៃ | ០១ រូប | សមាជិក |
| - តំណាងក្រសួងរ៉ែ និងថាមពល | ០១ រូប | សមាជិក |
| - តំណាងរដ្ឋបាលរាជធានីភ្នំពេញ | ០១ រូប | សមាជិក |
| - អគ្គនាយករបស់ **ស.ឆ.ស.** | ០១ រូប | សមាជិក |
| - តំណាងបុគ្គលិករបស់ **ស.ឆ.ស.** | ០១ រូប | សមាជិក។ |

ប្រធាន និងសមាជិកក្រុមប្រឹក្សាភិបាលដែលមានសមាសភាពពីវិស័យសាធារណៈ លើកលែងតែតំណាងបុគ្គលិក ត្រូវតែងតាំងសម្រាប់អាណត្តិ៣ឆ្នាំ ហើយអាចបន្តជាថ្មីទៀតបានដោយអនុក្រឹត្យតាមសំណើ របស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន។

តំណាងបុគ្គលិក ត្រូវជ្រើសរើសដោយការបោះឆ្នោត ក្នុងចំណោមបុគ្គលិករបស់ **ស.ឆ.ស.**។

សមាសភាពក្រុមប្រឹក្សាភិបាលអាចត្រូវបានបញ្ចប់មុនអាណត្តិ តាមសំណើរបស់ក្រសួង-ស្ថាប័នតំណាង ក្នុងករណី សមាជិកក្រុមប្រឹក្សាភិបាល មានជាអាទិ៍ បាត់បង់ភាពស្របច្បាប់ជាតំណាងក្រសួង-ស្ថាប័ន ឬតំណាងបុគ្គលិករបស់ **ស.ឆ.ស.** ទទួលមរណភាព សុំលាឈប់ជាលាយលក្ខណ៍អក្សរ បាត់បង់សម្បទាវិជ្ជាជីវៈដោយមានលិខិតបញ្ជាក់ពីក្រសួង-ស្ថាប័នមានសមត្ថកិច្ច ឬត្រូវបានផ្តន្ទាទោសឱ្យជាប់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិមណាមួយ។

**មាត្រា ៨ ._**

ក្រសួងអាណាព្យាបាលបច្ចេកទេស ត្រូវទទួលខុសត្រូវក្នុងការបំពេញទម្រង់បែបបទនានានៃការបង្កើតក្រុមហ៊ុន ដែលមានជាអាទិ៍÷

- រៀបចំលក្ខន្តិកៈរបស់ក្រុមហ៊ុនដោយមានការឯកភាពពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រៀបចំលក្ខន្តិកៈបុគ្គលិក
- ចាត់ចែងចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម
- បំពេញទម្រង់បែបបទទាំងអស់ស្របតាមគោលការណ៍ និងបែបបទទាំងឡាយនៃនីតិក្រុមហ៊ុនពាណិជ្ជកម្ម។

**មាត្រា ៩ ._**

ការងារប្រចាំថ្ងៃរបស់ **ស.ឆ.ស.** ត្រូវដឹកនាំដោយ "**អគ្គនាយក**" ០១ រូប ដែលត្រូវបានជ្រើសរើសចេញពីវិស័យសាធារណៈ ឬ វិស័យឯកជន ដោយឈរលើគោលការណ៍នៃការប្រកួតប្រជែង បើកចំហ និងតម្លាភាព ផ្អែកលើសមត្ថភាពនិងបទពិសោធន៍ក្នុងវិស័យធុរកិច្ច ឬវិស័យគ្រប់គ្រងបរិស្ថាន និងនគរូបនីយកម្ម។

អគ្គនាយកត្រូវតែងតាំងដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន។

**មាត្រា ១០ ._**

ភារកិច្ច និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាភិបាល ព្រមទាំងភារកិច្ចរបស់អគ្គនាយក **ស.ឆ.ស.** ត្រូវកំណត់ដោយលក្ខន្តិកៈសហគ្រាស ដែលការរៀបចំលក្ខន្តិកៈនោះ ត្រូវស្របតាមអនុក្រឹត្យនេះ, ច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ និងច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម។

លាភការរបស់ក្រុមប្រឹក្សាភិបាល និងប្រាក់បំណាច់របស់អគ្គនាយក **ស.ឆ.ស.** ត្រូវកំណត់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើរបស់ក្រុមប្រឹក្សាភិបាល។

**មាត្រា ១១ ._**

បុគ្គលិករបស់ **ស.ឆ.ស.** ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងនៃលក្ខន្តិកៈបុគ្គលិកដែលសម្រេចដោយក្រុមប្រឹក្សាភិបាល។

ការរៀបចំលក្ខន្តិកៈបុគ្គលិកនេះ ត្រូវកំណត់កាតព្វកិច្ច និងសិទ្ធិរបស់និយោជិតមានជាអាទិ៍ ការជ្រើសរើស ការវិវត្តនៃអាជីព ការបញ្ឈប់មុខងារ ការផ្តល់លាភការ ការផ្តល់អត្ថប្រយោជន៍ និងការដាក់ទណ្ឌកម្ម ព្រមទាំងត្រូវអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនីតិការងារ។

**មាត្រា ១២ ._**

ការដឹកនាំ និងការគ្រប់គ្រងលើកិច្ចប្រតិបត្តិការអាជីវកម្ម និងការផ្តល់សេវាកម្ម របស់ **ស.ឱ.ស.** ត្រូវអនុលោមតាមបទប្បញ្ញត្តិនៃលក្ខន្តិកៈសហគ្រាស និងលក្ខន្តិកៈបុគ្គលិក ព្រមទាំងច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមានដែលពាក់ព័ន្ធទៅនឹងការរៀបចំ និងការប្រព្រឹត្តទៅនៃសហគ្រាសសាធារណៈ។

## ជំពូកទី៤
## ការគ្រប់គ្រងហិរញ្ញវត្ថុ និងប្រភពធនធាន

**មាត្រា ១៣ ._**

**ស.ឱ.ស.** ត្រូវកាន់កិច្ចបញ្ជិកាគណនេយ្យ ស្របតាមបទបញ្ញាគណនេយ្យនៃកម្ពុជា និងតាមវិធានស្តង់ដាគណនេយ្យរបស់ក្រុមហ៊ុនពាណិជ្ជកម្ម ដែលកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ បញ្ជីគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុ ត្រូវធ្វើជាភាសាខ្មែរ និងជាប្រាក់រៀល។

ការិយបរិច្ឆេទគណនេយ្យនីមួយៗរបស់ **ស.ឱ.ស.** ត្រូវកំណត់រយៈពេល ១២ (ដប់ពីរ) ខែ ដោយគិតចាប់ពីថ្ងៃទី០១ ខែមករា រហូតដល់កាលបរិច្ឆេទបិទបញ្ជីគណនេយ្យនៅថ្ងៃទី ៣១ ខែ ធ្នូ នៃឆ្នាំ ដែល។

របាយការណ៍ហិរញ្ញវត្ថុ របស់ **ស.ឱ.ស.** ជាកម្មវត្ថុនៃការត្រួតពិនិត្យ និងការធ្វើសវនកម្មពីក្រសួងអាណាព្យាបាល និងក្រសួង-ស្ថាប័នដែលមានសមត្ថកិច្ចពាក់ព័ន្ធតាមការចាំបាច់ដោយអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា ១៤ ._**

យ៉ាងយូរបំផុតនៅថ្ងៃទី ៣០ ខែ កញ្ញា នៃឆ្នាំបន្ទាប់ ក្រុមប្រឹក្សាភិបាលត្រូវផ្តល់ការអនុម័តលើគម្រោងអាជីវកម្ម សេវាកម្ម និងវិនិយោគប្រចាំឆ្នាំ របស់ **ស.ឱ.ស.** តាមសំណើរបស់អគ្គនាយក។ គម្រោងអាជីវកម្ម សេវាកម្ម និងវិនិយោគប្រចាំឆ្នាំត្រូវទទួលការយល់ព្រមពីក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ការរៀបចំគម្រោងនេះ ត្រូវបញ្ជាក់ជាអាទិ៍នូវ៖

- លក្ខណៈវិនិច្ឆ័យសម្រាប់វាស់វែងលទ្ធផលសេដ្ឋកិច្ច និងហិរញ្ញវត្ថុរបស់ **ស.ឱ.ស.**
- ថវិកាសម្រាប់ដំណើរការនៃសហគ្រាស ត្រូវផ្សារភ្ជាប់នឹងស្ថានភាពអាជីវកម្ម សេវាកម្ម និងគោលដៅវិនិយោគរបស់សហគ្រាស
- គម្រោងវិនិយោគឆ្នាំនីមួយៗ ត្រូវរៀបចំស្របតាមកម្មវិធីវិនិយោគដែលបានកំណត់ទុកស្ថានភាពរំហូរសាច់ប្រាក់ ព្រមទាំងហិរញ្ញប្បទានបម្រុងសម្រាប់សម្រេចកម្មវិធីវិនិយោគនេះ។

**មាត្រា ១៥ ._**

**ស.ឱ.ស.** មានប្រភពធនធាន ជាអាទិ៍៖

- ដើមទុនដំបូងបានមកពីថវិកាជាតិ សម្រាប់វិនិយោគ និងដំណើរការសេវាកម្ម

- ចំណូលចរន្តពីការបង់ថ្លៃសេវាទុកដាក់សំរាម សំណល់រឹង ពីអ្នកប្រើប្រាស់ទីលាន
- ចំណូលចរន្តពីការបង់ថ្លៃសេវាគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធសមាហរណកម្ម
- ឧបត្ថម្ភធនបន្ថែមជាយថាហេតុ ពីរដ្ឋបាលថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ
- អំណោយ និងអច្ច័យទានផ្សេងៗ
- ចំណូលពីប្រភពស្របច្បាប់ផ្សេងទៀត។

**មាត្រា ១៦ ._**

ការបន្ថែម ឬ បន្ថយដើមទុនរបស់ **ស.ឆ.ស.** ត្រូវសម្រេចដោយក្រុមប្រឹក្សាភិបាល និងមានការយល់ព្រមជាមុនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយត្រូវអនុវត្តស្របតាមច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ព្រមទាំងបទប្បញ្ញត្តិហិរញ្ញវត្ថុជាធរមាន។

**មាត្រា ១៧ . _**

ត្រូវបានដាក់ឱ្យនៅអម **ស.ឆ.ស.** នូវមន្ត្រីត្រួតពិនិត្យរដ្ឋម្នាក់។ មន្ត្រីត្រួតពិនិត្យរដ្ឋ ត្រូវបានតែងតាំង និងបញ្ឈប់ពីតំណែងដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

មន្ត្រីត្រួតពិនិត្យរដ្ឋ មានសិទ្ធិចូលរួមក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល របស់ **ស.ឆ.ស.** ហើយអាចផ្តល់យោបល់ពិគ្រោះលើចំណុចក្នុងរបៀបវារៈនៃកិច្ចប្រជុំ តែពុំមានសិទ្ធិបោះឆ្នោតអនុម័តឡើយ។

មន្ត្រីត្រួតពិនិត្យរដ្ឋអម **ស.ឆ.ស.** ត្រូវបំពេញការងារត្រួតពិនិត្យស្របតាមច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

**មាត្រា ១៨ ._**

រយៈពេល១៥ថ្ងៃយ៉ាងយូរ ក្រោយពីការអនុម័តរបស់ក្រុមប្រឹក្សាភិបាល អគ្គនាយក **ស.ឆ.ស.** ត្រូវផ្ញើជូនរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអាណាព្យាបាល នូវឯកសារមានអាទិ៍÷

- កំណត់ហេតុប្រជុំក្រុមប្រឹក្សាភិបាល
- ថវិកាសម្រាប់ការប្រព្រឹត្តទៅនិងការវិនិយោគប្រចាំឆ្នាំ
- របាយការណ៍ស្តីពីសកម្មភាព គុណ្យការនិងគណនីគ្រប់គ្រង ព្រមទាំងឯកសារឧបសម្ព័ន្ធ
- របាយការណ៍ស្តីពីការត្រួតពិនិត្យគណនីនានា
- បញ្ជូនបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋទាំងអស់ ដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាល មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីតម្កល់ទុក និងធ្វើការពិនិត្យតាមដាន ព្រមទាំងរាយ-ការណ៍ជារៀងរាល់ឆ្នាំនូវលទ្ធផលនៃការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ។

## ជំពូកទី ៥
## អវសានប្បញ្ញត្តិ

**មាត្រា ១៩ ._**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ២០ ._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ច័ន្ទ ១ កើត ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ ២០២០

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន

សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**សាយ សំអាល់**

**<u>កន្លែងទទួល៖</u>**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច/ឯកឧត្តម/លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២០ ដើម្បីអនុវត្ត
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ